ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ៧០៦/២៥ គ.ជ.ប.ជ

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំត្រីមាសទី៣ និងទិសដៅត្រីមាសទី៤ ឆ្នាំ២០២៥

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើង ជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្សជារឿង ស្មុកស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិ ក្នុងពិភពលោក ដែលមិនមែនកើតឡើងដោយមូលហេតុតែមួយនោះទេ។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្តាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងព័ត៌មានពិត និងមិនពិត រួមទាំងនិន្នាការ នឹងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជាក៏បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្តែងនៅកម្ពុជា។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការ ទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានាក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជាដែលពេញវ័យការងារ ឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ កន្លងមកចំនួនដ៏ច្រើនលើសលុបនៃប្រជាជនពេញវ័យការងារបានធ្វើចំណាកស្រុក មានរហូតដល់ជាងមួយលាននាក់ បាននិងកំពុងនៅធ្វើការងាររហូតដល់ប្រមាណ១.៦លាននាក់ នៅក្រៅប្រទេស ដែលស្មើនឹងជិត២០ភាគរយ នៃប្រជាពលរដ្ឋវ័យ ពី១៥ឆ្នាំ ទៅ ៦០ឆ្នាំ និងអត្រាដ៏ខ្ពស់នៃការបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា បានប៉ះពាល់ទៅនឹងកង្វះធនធានពលកម្ម សម្រាប់ទទួលយកការងារដែលត្រូវបានបង្កើតឡើងក្នុងស្រុក តាមរយៈការវិនិយោគលើវិស័យឧស្សាហកម្ម និងសហគ្រាសធំៗ ដែលរាជរដ្ឋាភិបាលបាននិងកំពុងទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិ។ ក្នុងអំឡុងពេលនៃភាពតានតឹងនយោបាយរវាង កម្ពុជា ថៃ ពលករកម្ពុជាបានវិលត្រលប់ប្រមាណជិត ១លាននាក់ ពីប្រទេសថៃ។ ការវិលត្រឡប់នៃពលករកម្ពុជា មកមាតុភូមិវិញ បានបង្កើតឱកាសផង និងការប្រឈមផង ដែលរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ នឹងគិតគូរដោះស្រាយ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ នៃសង្គមជាតិ។

នៅក្នុងត្រីមាសទី៣នេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី-ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រសហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ

#### ក.១. កិច្ចសហប្រតិបត្តិការ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះអនុស្សរណៈនៃការយោគយល់ ជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) ស្តីពី «សកម្មភាពបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកម្លាំងពលរដ្ឋក្នុងបរិបទទេសន្តរប្រវេសន៍ (២០២៥-២០២៨)» ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ៤៥.៣៥៦លើក មានអ្នកចូលរួមសរុបចំនួន ២.២៣៥.៨៦៥នាក់ ក្នុងនោះស្ត្រី ១.២១៨.៣១៤នាក់ (ប្រៀបធៀបត្រីមាសទី២ ឆ្នាំ២០២៥ មានចំនួន ២.៧២៣.៥០៧នាក់) ថយចុះប្រមាណ ១៧,៩០% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស | ០៣ | ៣.០៩៧ | ៩០៤ |
| ២ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ៤៤.៣៤៧ | ២.០៩៩.៩២២ | ១.១៦៤.៣២៥ |
| ៣ | កម្មវិធីផ្សេងៗ | ១.០០៦ | ១៣២.៨៤៦ | ៥៣.០៨៥ |
| សរុប | | ៤៥.៣៥៦លើក | ២.២៣៥.៨៦៥នាក់ | ១.២១៨.៣១៤នាក់ |

*(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)*

❖ **ទិវាជាតិអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្ស ២០សីហា**

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសហការជាមួយ ក្រសួងធម្មការនិងសាសនា និងមេដឹកនាំនិកាយសាសនាធំៗ ក្នុងព្រះរាជាណាចក្រកម្ពុជា (សាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រីស្ត) រៀបចំកម្មវិធីទិវាជាតិអន្តរសាសនាលើកទី៩ ឆ្នាំ២០២៥ ក្រោមប្រធានបទ "សុខដុមរមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់នាសម័យបច្ចេកវិទ្យា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ **កែ សួនសុភី ស សុខា** ជាទីគោរពដ៏ខ្ពង់ខ្ពស់។ មានអ្នកចូលរួមប្រមាណ ២.៤៨៥អង្គ/នាក់ (ស្រី ៧០៩នាក់) នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ(OCIC) រាជធានីភ្នំពេញ។

▪ **ខេត្តសៀមរាប និងខេត្តស្វាយរៀង៖** លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយមន្ទីរធម្មការ និងសាសនាខេត្ត និងអង្គការដៃគូ រៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ក្រោមប្រធានបទ «សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នាសម័យបច្ចេកវិទ្យា» ដោយមានការនិមន្តចូលរួម ពីតំណាងសាសនាព្រះពុទ្ធទាំងពីរគណៈ សាសនាឥស្លាម សាសនាគ្រីស្តពីរនិកាយ ពុទ្ធសាសនាមហាយាន និងតំណាងមន្ទីរ អង្គភាព ស្ថាប័ន គណៈអភិបាលក្រុង ស្រុក ចៅសង្កាត់ និងអង្គការដៃគូជាតិ-អន្តរជាតិ សរុបជាង **៦១២អង្គ/នាក់** (ស្រី ១៩៥នាក់)។

## ❖ ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ២០៩ | ៥៤.៥៥៣ | ២៨.៣១៤ | ៧០ | ៤.៨៣០ | ២.៥៥៨ |
| ២ | កណ្ដាល | ២១៤ | ២០.១៦៤ | ១២.០២១ | ៤៩៦ | ១៣.៤១៨ | ៧.០៩៤ |
| ៣ | បាត់ដំបង | ២.៣៧១ | ១០៤.៤៦៨ | ៦០.៣៩៦ | ២.០២៩ | ៧៣.៣៧៦ | ៤៦.១១៥ |
| ៤ | ពោធិ៍សាត់ | ២.៣៦៨ | ២៣១.៥២៥ | ១០៤.២០៩ | ១.២៤១ | ៥១.១៤០ | ២៥.៩៧៦ |
| ៥ | សៀមរាប | ២.២១៥ | ១២៩.៣០៥ | ១០៦.៥០៦ | ១.៨១០ | ៧៣.៣៣៣ | ៤៦.៩១៥ |
| ៦ | កំពង់ឆ្នាំង | ២.១៥៣ | ៨៦.៩០៤ | ៤៨.៦០០ | ៧០៨ | ២៨.៣៨១ | ១៤.៩៤៤ |
| ៧ | កំពង់ចាម | ៥.១០៥ | ២៩៦.៩៦៥ | ១៥២.៩២២ | ២ | ២២៨ | ១១៣ |
| ៨ | ព្រះសីហនុ | ៥៥៦ | ១៦.១០៦ | ៧.៣៧១ | ២៩៩ | ៨.៣៧១ | ៤.០៧៦ |
| ៩ | ព្រះវិហារ | ១០៨ | ៨.៦៧៧ | ៥.៦៣៦ | | | |
| ១០ | ស្វាយរៀង | ១.២៧៨ | ៤៩.១០៤ | ២៧.៧២៩ | ១.៦៥៩ | ៦៩.០៨៧ | ៥០.៤៩៨ |
| ១១ | ប៉ៃលិន | ៣ | ១៩៨ | ១២១ | ២៩៩ | ១១.៥០៦ | ៥.៤៩៦ |
| ១២ | កោះកុង | ៤.០៧៥ | ៦៥.១៦៧ | ២៨.៨១២ | ៩០៥ | ១៦.៦៩៣ | ៦.៦៣៧ |
| ១៣ | កំពត | ៤០ | ៥០៤០ | ២.៤១០ | | | |
| ១៤ | កំពង់ធំ | ៦៥៦ | ៤១.៦៣០ | ២៥.០២៥ | ២២៩ | ៩.១០៧ | ៥.២៨៧ |
| ១៥ | តាកែវ | ៧២៦ | ៧៧.៨៤៣ | ៣៧.២៨៦ | | | |
| ១៦ | ក្រចេះ | ១៩៤ | ៥.៩៥៨ | ២.៣៨៣ | | | |
| ១៧ | កែប | ៥៧ | ៩.០៣០ | ៤.២៤០ | ១០៩ | ៤.៨០៣ | ២.៧៥៩ |
| ១៨ | កំពង់ស្ពឺ | ១.៦៤៦ | ៦៨.៩៨៧ | ៣៩.០៤២ | ៤៨៧ | ១៧.៦១១ | ៩.៩៨៤ |
| ១៩ | ស្ទឹងត្រែង | ៤៧៦ | ៣២.១៨៦ | ១៦.៧៣៥ | ៣៨៩ | ១៣.៧៩៨ | ៧.៦៦៦ |
| ២០ | រតនគិរី | ១.១៨១ | ៤៨.៩២៦ | ២៤.១៦១ | ៥៧៥ | ២៨.៦០០ | ១៣.៦៩៤ |
| ២១ | ព្រៃវែង | ៣.២២៧ | ១៦៥.៥០៣ | ៩៣.៧២១ | ១.៦២៧ | ៧៦.៦៣៩ | ៤២.៨៨៧ |
| ២២ | ត្បូងឃ្មុំ | ៣០ | ៦.១២៣ | ៣.២៨៨ | ៤៤៥ | ១៣.៤៤០ | ៦.៣២២ |
| ២៣ | បន្ទាយមានជ័យ | ១.០០៤ | ១៩.២៨៨ | ១០.៧២៣ | ៣០០ | ៧.៩៤៦ | ៤.៧៤៤ |
| ២៤ | ឧត្ដរមានជ័យ | ៤៣០ | ២២.៣៦៦ | ១៣.១៨០ | ៥២ | ២.៣៧២ | ១.២៨៦ |
| ២៥ | មណ្ឌលគិរី | ២៥១ | ៧.៣៧៥ | ៣.៥៧២ | ៤៣ | ១.៨៥២ | ៨៧១ |
| សរុប រាជធានី-ខេត្ត | | ៣០.៥៧៣ | ១.៥៧៣.៣៩១ | ៨៥៨.៤០៣ | ១៣.៧៧៤ | ៥២៦.៥៣១ | ៣០៥.៩២២ |
| សរុបរួម | | ៤៤.៣៤៧លើក | | ២.០៩៩.៩២២នាក់ | | ១.១៦៤.៣២៥នាក់ | |

## ❖ ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០៣ | ៥៨០ | |
| ២ | ខេត្តកណ្ដាល | ១៩ | ១៣.២៣៤ | ៦.១៣៣ |
| ៣ | ខេត្តបាត់ដំបង | ៩ | ៥៣៧ | ១៩១ |
| ៤ | ខេត្តប៉ៃលិន | ៤ | ៣.៩២៣ | ២.២៦០ |
| ៥ | ខេត្តសៀមរាប | ១៣៩ | ៦.៤២៤ | ៣.៦៨៤ |
| ៦ | ខេត្តកំពង់ចាម | ៤ | ២៧២ | ១៥២ |
| ៧ | ខេត្តព្រះវិហារ | ៣ | ៦៩ | ២២ |

| | | | | |
|---|---|---|---|---|
| ៨ | ខេត្តព្រៃវែង | ១០ | ២.៨៣០ | ១៧៨ |
| ៩ | ខេត្តត្បូងឃ្មុំ | ៨ | ៧៧៥ | ៣៨៨ |
| ១០ | ខេត្តឧត្តរមានជ័យ | ៤៥៤ | ១.៧១៤៦ | ១០.៥៦១ |
| ១១ | ខេត្តកំពង់ស្ពឺ | ៤៥ | ២៩.៣៣៥ | ៤៤៩ |
| ១២ | ខេត្តមណ្ឌលគិរី | ១ | ១៧៥ | ៨៣ |
| ១៣ | ខេត្តតាកែវ | ៩៨ | ៥០.៨៤០ | ២.៥៥១៤ |
| ១៤ | អង្គការតំណាង់ទឹក(បន្ទាយមានជ័យ) | ៣ | ១៤៨ | ៨០ |
| ១៥ | អង្គការ Friend Insertional(សៀមរាប) | ១៤៥ | ២.៤២២ | ១.២០៤ |
| ១៦ | អង្គការសាម៉ារីតាន់ភឺស(បាត់ដំបង) | ៣ | ១.៤០៤ | ៧៦៥ |
| សរុប | | ១.០០៦លើក | ១៣២.៨៤៦នាក់ | ៥៣.០៨៥នាក់ |

**ខ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់**

❖ **ការផលិត និងចែកផ្សាយសម្ភារផ្តល់ព័ត៌មាន និងអប់រំ** (IEC = Information Education Communication Materials)

| ល.រ | រាជធានី-ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|
| ១ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ២៨.១៥៨ប័ណ្ណ | | |
| ២ | បាត់ដំបង | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៥.២៦១ប័ណ្ណ | | |
| ៣ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ២.៣២៥ប័ណ្ណ | | |
| ៤ | បន្ទាយមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | | ១.៧៤២នាក់ | ៦៧៨នាក់ |
| ៥ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ២៦ប័ណ្ណ | ៩៤៥នាក់ | ២៥៨នាក់ |
| | សរុប | | ៣៥.៧៧០ប័ណ្ណ | ២.៦៨៧នាក់ | ៩៣៦នាក់ |

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

| ល.រ | ក្រសួង ស្ថាប័ន រាជធានី-ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក/ដង/ស្ប៊ត | ចំនួនអ្នកទស្សនា/ស្តាប់/អាន/Views |
|---|---|---|---|---|
| ១ | គ.ជ.ប.ជ | -បណ្តាញទូរស័ព្ទ | ០១ | |
| ២ | សៀមរាប | -វិទ្យុជាតិ<br>-សម្តែងរឿងខ្លី | ២៩៤<br>០១ | ៥០(ស្រី២៥) |
| ៣ | កំពង់ចាម | -វិទ្យុជាតិ | ៩០០ | |
| ៤ | ព្រៃវែង | -វិទ្យុជាតិ | ១០០ | |
| ៥ | ត្បូងឃ្មុំ | -វិទ្យុជាតិ | ៦៤ | |
| ៦ | ប៉ៃលិន | -វិទ្យុជាតិ | ៩៩២ | |
| ៧ | បន្ទាយមានជ័យ | -វិទ្យុជាតិ | ២០ | |
| សរុប | | | ២.៣៧២ លើក | ៥០(ស្រី២៥) |

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍**

▪ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃគ.ជ.ប.ជ ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានផ្តល់បទសម្ភាសន៍ជូនអង្គការ Terre des Hommes Netherland ពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសការងារប្រយុទ្ធប្រឆាំងការរំលោភបំពាន និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ។

▪ លេខាធិការដ្ឋានរាជធានី-ខេត្ត មានខេត្ត(សៀមរាប បាត់ដំបង និងកំពង់ចាម) បានចូលរួមជាវាគ្មិន តាមវិទ្យុជាតិខេត្ត ក្រោមប្រធានបទ "នីតិវិធីធ្វើការដោយស្របច្បាប់នៅប្រទេសថៃ និងយន្តការទទួល ការដោះស្រាយបណ្តឹង" "ផលប៉ះពាល់លើកុមារដោយសារការធ្វើចំណាកស្រុករបស់គ្រួសារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព" "ការទទួល និងត្រៀមកន្លែងការងារសម្រាប់ពលករមកពីប្រទេសថៃ" និង"ការយល់ដឹង និងរួមគ្នាបង្ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ និងកុមារតាមប្រព័ន្ធអនឡាញ" សរុបបាន ១៦លើក។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១ ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរដែលបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ចំនួន ១៧លើក មនុស្សចំនួន ២០៥នាក់ ស្រី ៩៤នាក់ ដោយបានធ្វើកិច្ចសន្យាអប់រំណែនាំ និងឱ្យត្រឡប់ទៅភូមិកំណើតវិញ។

### ខ.៣.២. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ចំនួន ២៧៤នាក់ ស្រី ២៦នាក់ មាន ១៩សញ្ជាតិ និងវាយតម្លៃបញ្ជូនទៅក្រុមការងារចម្រុះច្រកចេញ-ចូលតែមួយចំនួន ៦១៦នាក់ ស្រី ២៨នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| បរិយាយ | ចំនួនមនុស្ស | សញ្ជាតិ |
|---|---|---|
| ប្រុសបរទេសជាមួយស្រីខ្មែរ | ៥៤៨នាក់ | ចិន៣៦៣, កូរ៉េខាងត្បូង១១៣ស្រី១៤, អាម៉េរិក៤២ស្រី៤, បារាំង១០ស្រី២, ម៉ាឡេស៊ី៩ស្រី១, អូស្ត្រាលី៩ស្រី២, ឥណ្ឌូនេស៊ី៥, វៀតណាម៥នាក់ស្រី២, ជប៉ុន៣, ស្រីលង្កា២, កាណាដា២, ឡាវ១(ស្រី), អង់គ្លេស១, ស្វីស១, រុស្ស៊ី១, ទួគី១, អាល្លឺម៉ង់៤, ម៉ាល់១ និងអាហ្វ្រិកខាងត្បូង១។ |
| ស្រីបរទេសជាមួយបុរសខ្មែរ | ២៦នាក់ | |
| សរុប | ២៧៤ នាក់ | ១៩ សញ្ជាតិ |

❖ ការផ្សព្វផ្សាយ

▪ **ខេត្តកំពង់ចាម៖** ផ្សព្វផ្សាយស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងខ្មែរ និងជនបរទេស ដក់ប្រជាពលរដ្ឋក្នុងក្រុងកំពង់ចាមបាន ៦២លើក មនុស្សចូលរួមចំនួន ៣.៤១នាក់ ស្រី ២.២៧៦នាក់។

### ខ.៣.៣. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

អគ្គស្នងការដ្ឋាននគរបាលជាតិ បានតាមដាន និងធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរធ្វើចំណាកស្រុកទៅទៅរកការងារធ្វើនៅក្រៅប្រទេស និងត្រឡប់មកវិញ តាមរយៈការប្រមូលទិន្នន័យពីបណ្តាស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងប្រទេស មានដូចខាងក្រោម៖

- ទិន្នន័យពលរដ្ឋខ្មែរធ្វើចំណាកស្រុកទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងពីអាណាព្យាបាល និងក្រុមគ្រួសារ ចំនួន ១២៩.៧២២នាក់ ស្រី ៥៨.០៥៦នាក់ អនីតិជន ៥១.១៦នាក់ ស្រី ១.៦២៥នាក់ ក្នុងនោះស្របច្បាប់ចំនួន ១១០.៧៨៣នាក់ ស្រី ៤៩.២៣៦នាក់ អនីតិជន ២.១៣១នាក់ ស្រី ៥៩៩នាក់, មិនស្របច្បាប់ចំនួន ១.៨២៥៣នាក់ ស្រី ៨.៥១៨នាក់ អនីតិជន ២.៨៧៨នាក់ ស្រី ៩៩៦នាក់ និងដាច់ការទាក់ទងចំនួន ៦៨៦នាក់ ស្រី ៣០២នាក់ អនីតិជន ១០៧នាក់ ស្រី ៣០នាក់។

- ទិន្នន័យពលរដ្ឋខ្មែរធ្វើចំណាកស្រុកត្រឡប់ពីក្រៅប្រទេសវិញទាំងស្របច្បាប់ និងមិនស្របច្បាប់ចំនួន ១៤.៦៨៤នាក់ ស្រី ៦.០១៩នាក់ អនីតិជន ២១២នាក់ ស្រី ៧៩នាក់។

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

+ ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន

| ល.រ | រាជធានី-ខេត្ត | ចំនួនរួម | ស្រី | អនីតិជន | ស្រី |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៣.៨០៥ | ១.២៨៩ | | |
| ២ | បាត់ដំបង | ១២៤ | ៣៤ | | |
| ៣ | កោះកុង | ៣៦ | ០៦ | | |
| ៤ | ប៉ៃលិន | ១០.៤៤២ | ៤.៦៨២ | | |
| ៥ | ស្វាយរៀង | ២៧ | ២១ | ០៥ | ០៣ |
| | សរុប | ១៤.៤៣៤នាក់ | ៦.០៣២នាក់ | ០៥នាក់ | ០៣នាក់ |

+ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត បានទទួលពលករខ្មែរចំណាកស្រុកដែលបញ្ជូនត្រឡប់ពីប្រទេសថៃនិរទេស សរុបចំនួន ៣.២៨២នាក់ (ប្រុស១.៧៣៣នាក់ ស្រី១.១២៤នាក់ កុមារា ២២៥នាក់ កុមារី២០០នាក់)។

**ខ.៤. ការលើកកម្ពស់ជីវភាព**

❖ ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

▪ **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មជ្ឈមណ្ឌលការងារខេត្ត វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ និងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប បានសហការជាមួយរដ្ឋបាលខេត្តសៀមរាប ទីភ្នាក់ងារជាតិមុខរបរនិងការងារ រដ្ឋបាលស្រុកក្រឡាញ់ ស្រុកអង្គរជុំ ស្រុកពួក ស្រុកសូទ្រនិគម ស្រុកជីក្រែង និងក្រុមហ៊ុនវិស័យឯកជន បានចុះយុទ្ធនាការរៀបចំវេទិកាការងារ និងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដល់យុវជនក្រុមគោលដៅ និងពលករដែលទើបវិលត្រឡប់មកពីប្រទេសថៃ ចំនួន ២៨លើក មានអ្នកចូលរួមចំនួន ៧.៧៣០នាក់ ស្រី ៣.៩០១នាក់។ ក្នុងនោះពលករសរុប ៥.៣៥០នាក់ ស្រី ២.៥៦៤នាក់ និងអ្នកចុះឈ្មោះស្វែងរកការងារធ្វើចំនួន ៣.២៤២នាក់ ស្រី ១.៨៣៥នាក់។

▪ **ខេត្តព្រៃវែង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមកម្មវិធីវេទិកាការងារ និងការផ្សព្វផ្សាយចូលរៀនជំនាញវិជ្ជាជីវៈ និងបច្ចេកទេស១.៥M ដល់ប្រជាពលរដ្ឋដែលងាយរងហានិភ័យ និងមានប័ណ្ណក្រីក្រនៅស្រុកស្វាយអន្ទរ, កំចាយមារ, ព្រះស្តេច, កញ្ជៀច, ស៊ីធរកណ្តាល និងស្រុកពារាំង អ្នកចូលរួមចំនួន ១៩.៦៩៤នាក់ ស្រី ៨.៥៥៧នាក់ ក្នុងនោះចំនួនផ្គូរផ្គងអ្នកស្វែងរកការងារទៅនិយោជក ២.២៣៤នាក់ ស្រី១.១២២នាក់។

▪ **ខេត្តប៉ៃលិន៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត

- បានសហការជាមួយអាជ្ញាធរមូលដ្ឋានតាមឃុំ-សង្កាត់ ធ្វើការផ្សព្វផ្សាយ និងជួយស្វែងរកការងារជូនបងប្អូនពលករខ្មែរ ដែលបានវិលត្រលប់មកពីប្រទេសថៃបានចំនួន ៤៣៥នាក់ ស្រី ១៩៣នាក់។
- បានចុះស្រង់ស្ថិតិតាមសហគ្រាសគ្រឹះស្ថាន ដែលកំពុងមានតម្រូវការជ្រើសរើសកម្មករនិយោជិតដោយបច្ចុប្បន្នមាន ៣៦សហគ្រាសគ្រឹះស្ថាន កំពុងមានតម្រូវការកម្មករនិយោជិតសរុប ១.១៥២នាក់ ស្រី ៧៣៥នាក់។

▪ **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមកម្មវិធី "វេទិកាការងារ" ចំនួន ២៤ឃុំ ក្នុង៦ស្រុក ក្នុងនោះមានស្រុក៖ (សំឡូត, បវេល, មោងឫស្សី, ថ្មគោល, កំរៀង, បាណន់) សរុបអ្នកចូលរួមចំនួន ៦.៥៤០នាក់ ស្រី ៣.៥០២នាក់។

▪ ខេត្តកំពង់ចាមៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុមការងារសម្របសម្រួល និងជួយរកការងារឱ្យពលករធ្វើ បានសហការជាមួយអាជ្ញាធរ ទីភ្នាក់ងារជាតិមុខរបរ និងការងារ ប.ស.ស និងវិទ្យាស្ថានពហុបច្ចេកទេសខេត្ត ចុះផ្សព្វផ្សាយ និងចុះឈ្មោះពលកររកការងារធ្វើបានចំនួន ២.២០៤នាក់ ស្រី ៩៧៩នាក់ ក្នុងនោះមានការងារធ្វើ និងប្រកបមុខរបរដោយផ្ទាល់ខ្លួនចំនួន ១.៥៧៤នាក់ ស្រី ៦៩៥នាក់ និងពលករចំនួន ២៨នាក់ ស្រី ១២នាក់ បានចុះឈ្មោះចូលរៀនជំនាញបច្ចេកទេសវិជ្ជាជីវៈ។

▪ ខេត្តកំពង់ស្ពឺ

- មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីការចិញ្ចឹមត្រី ធ្វើជីកំប៉ុស្ត ដើម្បីបង្កើនជីវភាព និងចំណេះដឹងជំនាញនៅក្នុងគ្រួសារ ដល់ប្រជាពលពលរដ្ឋចំនួន ០៧វគ្គ អ្នកចូលរួមចំនួន ១៤០នាក់ ស្រី ៤៤នាក់។

- មន្ទីរកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ បើកវគ្គបណ្តុះបណ្តាល ស្តីពីការចុះផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសគាំទ្រកសិកម្មចំនួន ០៩វគ្គ អ្នកចូលរួមចំនួន ២៣៥នាក់ ស្រី ៧១នាក់។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ៨១ករណី (ប្រៀបធៀបត្រីមាសទី២ ឆ្នាំ២០២៤ មានចំនួន ៥៥ករណី កើនឡើង ២៦ករណី) ស្មើនឹង៤៧,២៧% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ចំនួន ១៤៤នាក់ ស្រី ១៤នាក់ ជនបរទេស ២២នាក់ (ចិន ១៤នាក់ វៀតណាម ០៤នាក់ ថៃ ០៣នាក់ ម៉ាឡេស៊ី ០១នាក់)។
- សង្គ្រោះជនរងគ្រោះចំនួន ៣០៧នាក់ ស្រី ១៥៩នាក់ មានអាយុក្រោម១៥ឆ្នាំ ២៨នាក់ អាយុ១៥-១៧ឆ្នាំ ២៤នាក់ និងអាយុ១៨ឆ្នាំឡើង ២៥៥នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៩៣នាក់ គ្រួសារ ២១៤នាក់)។ ក្នុងនោះបែកជាៈ

**ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន ៥២/១៣ករណី (កើនឡើង ៣៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៩៣នាក់ ជនបរទេស ០៩នាក់(ចិន ០៦នាក់ ថៃ ០៣នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ២៤៤នាក់ ស្រី ៩៧នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ អាយុ១៥-១៧ឆ្នាំ ១៣នាក់ អាយុ១៨ឆ្នាំឡើង ២២២នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៥២នាក់ គ្រួសារ ១៩២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០១ | | ០១ |
| ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០១ | ០១ | | ០១ |
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ៣៦ | ៣៣ | ថៃ៣ | ១៥៤ |
| ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០២ | | ០១ |
| អំពើលក់ដូរមនុស្ស | ០២ | ០៦ | ចិន២ | ០៨ |
| ការដឹកជញ្ជូនដោយមានគោលដៅ | ០៧ | ២៣ | ចិន៤ | ១៦ |

| | | | | |
|---|---|---|---|---|
| អំពើនាំឆ្លងដែន | ០២ | ០៣ | | ០៧ |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជល្មើស | ១២ | ២៤ | | ៥៦ |
| *សរុប* | *៥២ករណី* | *៩៣នាក់* | *០៩នាក់* | *២៤៤នាក់* |

- **<u>ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ</u>**

បង្ក្រាបបាន ២៩/៤២ករណី (ថយចុះ ១៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៥១នាក់ ស្រី ០៧នាក់ ជនបរទេស ១៣នាក់(ចិន ០៨នាក់ វៀតណាម ០៤នាក់ ម៉ាឡេស៊ី ០១នាក់) សង្គ្រោះជនរងគ្រោះចំនួន ៦៣នាក់ ស្រី ៦២នាក់ មានអាយុក្រោម១៥ឆ្នាំ ១៩នាក់ អាយុ១៥-១៧ឆ្នាំ ១១នាក់ និងអាយុ១៨ឆ្នាំឡើង ៣៣នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៤១នាក់ គ្រួសារ ២២នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០២ | ០៤ | វៀតណាម៤ | ០២ |
| ស្ថានទម្ងន់ទោសនៃសញ្ញារកម្ម | ០១ | ០២ | ចិន២ | ២១ |
| សញ្ញារកម្មទាក់ទងនឹងពេស្យាចាកុមារ | ០៤ | ១១ | | ១៩ |
| រូបភាព និងសម្ភារៈអាសអាភាស | ០៣ | ១៤ | ចិន៦ ម៉ាឡេស៊ី១ | ០២ |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | | ០១ |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៤ | ១៥ | | ១៤ |
| អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ | | ០៤ |
| *សរុប* | *២៩ករណី* | *៥១នាក់* | *១៣នាក់* | *៦៣នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ

### ឃ.១. ការទទួល និងសម្ភាសពលករបញ្ជូនតាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈ នាយកដ្ឋានគាំពារជនរងគ្រោះ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សក្នុងប្រទេស និងពីក្រៅប្រទេស សរុបចំនួន ១២១នាក់(ប្រុស០៣នាក់ ស្រី៨៥នាក់ កុមារា០៥នាក់ កុមារី២៨នាក់)។ បានការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញចំនួន ១១៤នាក់(ស្រី៨២នាក់ កុមារា០៥នាក់ កុមារី២៧នាក់) ក្នុងនោះមាន៖

- ក្នុងប្រទេសចំនួន ៤៤នាក់(ស្រី៣០នាក់ កុមារា០៥នាក់ កុមារី០៩នាក់)
  - -ជនជាតិខ្មែរ ២៣នាក់(ស្រី០៩នាក់ កុមារា០៥នាក់ កុមារី០៩នាក់) ករណីសញ្ញារកម្ម ១៩នាក់ (ស្រី០៩នាក់ កុមារា០១នាក់ កុមារី០៩នាក់) និងករណីកម្លាំងពលកម្ម ០៤នាក់(កុមារា)
  - -ជនបរទេស ២១នាក់(ស្រី) មានជនជាតិឡាវ ១៦នាក់ វៀតណាម ០៤នាក់ និងចិន ០១នាក់ ករណីសញ្ញារកម្ម។
- ក្រៅប្រទេសចំនួន ៧៧នាក់(ប្រុស០៣នាក់ ស្រី៥៥នាក់ កុមារី១៩នាក់)
  - -ប្រទេសចិនចំនួន ៧០នាក់(ស្រី៥២នាក់ កុមារី១៨នាក់) ករណីអាពាហ៍ពិពាហ៍ផ្សំផ្គុំពីធន្ទះ
  - -ប្រទេសថៃចំនួន ០៧នាក់(ប្រុស០៣នាក់ ស្រី០៣នាក់ កុមារី០១នាក់) កេងប្រវ័ញ្ចកម្លាំងពលកម្ម ០២នាក់(ស្រី០១នាក់ កុមារី០១នាក់) និងបុគ្គលសង្ស័យថារងគ្រោះ ០៥នាក់ ស្រី០២នាក់។

**ឃ.២. ការផ្តល់សេវា**

មន្ទីរកិច្ចការនារីខេត្តព្រះសីហនុ ដោយទទួលកិច្ចសហការពីស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត និងអង្គការម្លប់តាប៉ាង បានផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្ត ដល់កុមារីរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទសរុបចំនួន ០៣នាក់ ព្រមទាំងឧបត្ថម្ភថវិកា ចំនួន ១០០,០០០រៀល ក្នុងមួយម្នាក់ និងសម្ភារៈប្រើប្រាស់របស់អង្គការ UNFPA។

**ឃ.៣. ការស្តារនីតិសម្បទា**

បានផ្តល់សេវាគាំទ្រ និងបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌល របស់អង្គការដៃគូចំនួន ១២១នាក់ (ប្រុស០៣នាក់ ស្រី៨៥នាក់ កុមារា០៥នាក់ កុមារី២៨នាក់)។ ទទួលសេវាមានដូចជា៖ អង្គការការពារសិទ្ធិកុមារ ហ៊ាគរ ៣៥នាក់ អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ ២១នាក់ អង្គការរតនៈអ៊ីន ជើណេសិនណល ១៧នាក់ អង្គការមូលនិធិហាការ ១១នាក់ អង្គការសម្ព័ន្ធចាប់ដៃ ០៩នាក់ អង្គការម៉ារីស៊ី ០៥នាក់ អង្គការមេត្រីអន្តរជាតិ ០៤នាក់ អង្គការIJM ០១នាក់ មជ្ឈមណ្ឌលស្តារនីតិសម្បទាប៉ោយប៉ែត ០៦នាក់ មណ្ឌលកុមារ កំព្រាភ្នំពេញ ០៤នាក់ អភិបាលខេត្តកណ្តាលទទួលយកទៅ ០៣នាក់ និងធ្វើកិច្ចសន្យាប្រគល់ទៅគ្រួសារ ០៥នាក់។

**ឃ.៤. ការធ្វើសមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យរងគ្រោះ**

បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្មជនរងគ្រោះ និងបុគ្គលសង្ស័យ រងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ត្រឡប់ទៅ សហគមន៍វិញសរុបចំនួន ៩៤នាក់ (ប្រុស០៧នាក់ ស្រី៦៨នាក់ កុមារី១៩នាក់)។

**ឃ.៥. ការធ្វើមាតុភូមិនិវត្តន៍**

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដែលត្រូវបាន ធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសដើមវិញ ចំនួន ២០នាក់(ស្រី) មានជនជាតិវៀតណាម ០៤នាក់ និងឡាវ ១៦នាក់។

**ឃ.៦. ការតាមដាន**

បានតាមដានករណីជនរងគ្រោះ និងបុគ្គសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវ កម្មផ្លូវភេទ ក្រោយពីធ្វើសមាហរណកម្មទៅសហគមន៍ ចំនួន ៣៣នាក់(ប្រុស០២នាក់ ស្រី១៣នាក់ កុមារា០១នាក់ កុមារី១៧នាក់)។

**ឃ.៧. ការបិទករណី**

បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ១៧នាក់(ស្រី១៤នាក់ កុមារី០៣នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការបណ្តុះបណ្តាល

❖ **ការបណ្តុះបណ្តាលក្នុងប្រទេស**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន និង គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.ក.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយ អង្គការដៃគូពាក់ព័ន្ធ រៀបចំបើកវគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាព គ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.ក.ប.ជ/គ.ខ.ប.ជ បានចំនួន ១៦វគ្គ មានសិក្ខាកាមចូលរួមចំនួន ១.១៨៩នាក់ ក្នុងនោះស្ត្រី ៤៦៥នាក់ ដូចមាន ក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាពវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ០១ | ៦២ | ៣៣ |
| ២ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ០២ | ៣៩៤ | ៧៩ |
| ៤ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០៣ | ៣៣០ | ១៤៩ |
| ៥ | ខេត្តបាត់ដំបង | ០១ | ៣៩ | ២០ |
| ៦ | ខេត្តសៀមរាប | ០៧ | ៣១៤ | ១៦៣ |
| ៧ | ខេត្តព្រៃវែង | ០១ | ០៩ | ០៩ |
| ៨ | ខេត្តព្រះសីហនុ | ០១ | ៤១ | ១២ |
| | **សរុបរួម** | **១៦វគ្គ** | **១.១៨៩នាក់** | **៤៦៥នាក់** |

**ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលស្តីពី៖**

១-ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

២-ការអនុវត្តតួនាទីភារកិច្ច ច្បាប់ គោលនយោបាយពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កិច្ចការពារកុមារពីការរំលោភបំពាននានា

៣-ទម្រង់របាយការណ៍និងឧបករណ៍ប្រមូលទិន្នន័យ ស្តីពីការផ្តល់សេវាគាំពារដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គម្រោងការអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ជនរងគ្រោះ ដែលរួចពីការជួញដូរមនុស្ស»

៤-ការផ្តល់សេវាដើម្បីឆ្លុះបញ្ចាំងពីការអនុវត្ត និងផលវិជ្ជមាន ពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព

៥-ការរៀបចំរបាយការណ៍ និងការគ្រប់គ្រងស្ថិតិពលករចំណាក-ចំណូលស្រុក

៦-បញ្ហានៃអំពើជួញដូរមនុស្ស និងការរំលោភបំពាននានា ជាពិសេសការរំលោភបំពានតាមប្រព័ន្ធអនឡាញ

៧-ការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ។

### ក.២. សិក្ខាសាលា

#### ❖ សិក្ខាសាលានៅក្នុងប្រទេស

ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.ប.ជ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយអង្គការ JICA អង្គការសម្ព័ន្ធចាប់ដៃ អង្គការនារីអភិវឌ្ឍន៍សេដ្ឋកិច្ចនិងអនាម័យ អង្គការមូលនិធិហាការអន្តរជាតិ អង្គការដៃកម្ពុជា និងអង្គការជីវិតនៅកម្ពុជា រៀបចំសិក្ខាសាលាដើម្បីពិគ្រោះយោបល់ និងផ្សព្វផ្សាយពង្រឹងសមត្ថភាពដល់មន្ត្រីពាក់ព័ន្ធ (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) បានចំនួន ០៤លើក មានសិក្ខាកាមចូលរួមចំនួន ៤៦២នាក់ ក្នុងនោះស្ត្រី ១៦៥នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាពសិក្ខាសាលា | ចំនួនលើក | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ស្តីពី«ការធ្វើបច្ចុប្បន្នភាពបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល»។ | ០១ | ៩៥ | ៣២ |
| ២ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** ស្តីពី «កិច្ចពិភាក្សាពិគ្រោះយោបល់ថ្នាក់ជាតិ ក្នុងការលើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការអនុវត្តនីតិវិធីសំណងរដ្ឋប្បវេណី»។ | ០១ | ១៤២ | ៦៨ |
| ៣ | **ខេត្តសៀមរាប** ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីដំណើររឿងក្តីនៃអំពើជួញដូរមនុស្ស ដល់មន្ត្រីនគរបាលយុត្តធម៌ មន្ត្រីសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិល។ | ០១ | ២០៣ | ៣៦ |

| | | | | |
|---|---|---|---|---|
| ៤ | ខេត្តព្រៃវែង ប្រកាសផ្សព្វផ្សាយ ដំណើរការអនុវត្តគម្រោង (សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញដំណាក់កាលទី២) ឆ្នាំ២០២៥។ | ០១ | ៦២ | ២៩ |
| សរុប | | ០៤ | ៤៦២នាក់ | ១៦៥នាក់ |

❖ **ការចូលរួមសិក្ខាសាលាក្រៅប្រទេស**

▪ ឯកឧត្តម ឧត្តមសេនីយ៍ទោ តែ សុថារេត អគ្គលេខាធិការរង បានអញ្ជើញទៅចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពី "ដំណោះស្រាយបញ្ហា ការធ្វើទេសន្តប្រវេសន៍មិនប្រក្រតី តាមរយៈយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ប្រកបដោយប្រសិទ្ធិភាព បង្ការទប់ស្កាត់ការជួញដូរមនុស្ស និងការរត់ពន្ធមនុស្សឆ្លងដែន នៅក្នុងរដ្ឋសមាជិកនៃ Bali Process" រៀបចំឡើងនៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ដោយការិយាល័យ គាំទ្រថ្នាក់តំបន់នៃ Bali Process (Regional Support Office: RSO) មានប្រទេសអូស្ត្រាលី និងប្រទេសឥណ្ឌូនេស៊ីជាដៃគូសហការរៀបចំរយៈពេល២ថ្ងៃ។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ **ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស**

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយគម្រោង JICA TRUST- រៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរួមលើកទី៣គម្រោង TRUST ការអភិវឌ្ឍសមត្ថភាពដើម្បីជួយដល់ជនរងគ្រោះដែលរួចពីការជួញដូរមនុស្សចំនួន ០១លើក អ្នកចូលរួមចំនួន ២៩នាក់ ស្រី ១១នាក់។

▪ **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានរៀបចំកិច្ចប្រជុំចំនួន ១០លើក អ្នកចូលរួមចំនួន ១៧៦នាក់ ស្រី ៥០នាក់ ក្នុងនោះមាន៖

- កិច្ចប្រជុំត្រៀមរៀបចំកម្មវិធីទិវាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៩ ឆ្នាំ២០២៥ ចំនួន ០៣លើក។

- កិច្ចប្រជុំអន្តរក្រសួងចំនួន ០២លើក ស្តីពីការត្រៀមកិច្ចពិភាក្សាពហុភាគីក្នុងតំបន់ ក្នុងការឆ្លើយទៅនឹងបទល្មើសជួញដូរមនុស្សឆ្លង ដែនពាក់ព័ន្ធនឹងបទល្មើសឆបោកតាមអនឡាញ ជាមួយតំណាងទូត នៃប្រទេសឡាវ, មីយ៉ាន់ម៉ា, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី និងអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលកម្ពុជាគ្រោងនឹងធ្វើជាម្ចាស់ផ្ទះ។ និងកិច្ចប្រជុំពិភាក្សា ដើម្បីពិនិត្យខ្លឹមសារសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់ រវាងគ.ជ.ប.ជ និងអង្គការមូលនិធិកុមារកម្ពុជា (CPU)។

- កិច្ចប្រជុំផ្ទៃក្នុង ចំនួន ០៥លើក៖ ពិនិត្យឆ្លងផែនការសកម្មភាព ឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ កែសម្រួលអនុស្សរណៈនៃការយោគយល់ រវាងគ.ជ.ប.ជ និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ។ ការអនុវត្តការងារប្រចាំថ្ងៃ លើតួនាទី ភារកិច្ចរបស់កងកម្លាំងនគរបាលគ្រប់ឋានានុក្រម នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ការរៀបចំរចនាសម្ព័ន្ធ អនុសាខា និងបណ្តាញ នៃគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ក្រសួងមហាផ្ទៃ។ ពិនិត្យ និងបំពេញបន្ថែមសេចក្តីព្រាងរបាយការណ៍ របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី។

▪ **លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ** មានខេត្តសៀមរាប, កណ្តាល, កំពង់ចាម, ព្រះវិហារ, ព្រៃវែង, ខេត្តរតនគីរី បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែកក្កដា ខែសីហា ខែកញ្ញា ត្រីមាសទី២ ត្រីមាសទី៣ និងឆមាសទី១ ឆ្នាំ២០២៥ សរុបចំនួន ១១លើក អ្នកចូលរួមចំនួន ៥៨៧នាក់ ស្រី ១០៩នាក់។

❖ **ការចូលរួមកិច្ចប្រជុំនៅក្រៅប្រទេស**

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចាត់បញ្ជូនលោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង ទៅចូលរួមប្រជុំនៅទីក្រុងម៉ាឡាកា ប្រទេសម៉ាឡេស៊ីចំនួន ៣ថ្ងៃ គឺ៖

(១).កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន SOMTC ត្រៀមសម្រាប់ AMMTC លើកទី១៩ និងកិច្ចប្រជុំពាក់ព័ន្ធ ដឹកនាំដោយ លោកជំទាវ **វីរក្ស វិជ្ជតា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តំណាងប្រធាន SOMTC កម្ពុជា និងអ្នកចូលរួម AMS ទាំង១០ប្រទេស រួមទាំងទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា +៣ ចិន ជប៉ុន កូរ៉េ សរុបចំនួន **១៨០រូប**។

(២).បើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៩ (AMMTC) និងកិច្ចប្រជុំពាក់ព័ន្ធ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន SOMTC កម្ពុជា និងអ្នកចូលរួម AMS ទាំង១០ប្រទេស និងប្រទេសទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា +៣ ចិន ជប៉ុន កូរ៉េ អ្នកអង្កេតការណ៍ សរុបចំនួន **៥០០រូប**។

(៣.)កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១ (AMMTC) និងកិច្ចប្រជុំពាក់ព័ន្ធ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម អភិសន្តិបណ្ឌិត **ស សុខា** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន AMMTC កម្ពុជា និងអ្នកចូលរួម AMS ទាំង១០ប្រទេស និងប្រទេសទីម័រ អគ្គលេខាធិការដ្ឋានអាស៊ាន ដៃគូសន្ទនា +៣ ចិន ជប៉ុន កូរ៉េ អ្នកអង្កេតការណ៍ ចំនួន **២៣០រូប**។

### ខ.២. ទស្សនកិច្ច

▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំគណៈប្រតិភូម្ចាស់ជំនួយនៃអង្គការការីតាសស្វីស ប្រចាំនៅកម្ពុជា ធ្វើទស្សនកិច្ចនៅមណ្ឌលទទួលពលករកំរៀងប្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ប្រកទ្វារអន្តរជាតិភ្នំដី ស្រុកសំពៅលូន ខេត្តបាត់ដំបង និងបានជួបសំណេះសំណាលជាមួយពលករ ដែលត្រូវបានបញ្ជូនត្រឡប់ពីប្រទេសថៃ។

### ខ.៣. ជំនួបពិភាក្សាការងារ

▪ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូគណៈកម្មការសាខាសមាគមនារីក្រសួងមហាផ្ទៃ ទទួលជួបតំណាងក្រុមហ៊ុន YHS Cambodia ដឹកនាំដោយ លោកស្រី **ហេង សុទ្ធាវី** អគ្គនាយិកា ដើម្បីពិនិត្យ និងពិភាក្សាការងារសម្រាប់កិច្ចសហការក្នុងការអនុវត្តសកម្មភាពមនុស្សធម៌ និងការងារសង្គម របស់សមាគមនារីក្រសួងមហាផ្ទៃ។ និងជាមួយតំណាងអង្គការសម្ព័ន្ធចាប់ដៃ ផ្តល់ការណែនាំសម្រាប់ការរៀបចំសិក្ខាសាលា ស្តីពី «កិច្ចពិភាក្សាពិគ្រោះយោបល់ថ្នាក់ជាតិ ក្នុងការលើកកម្ពស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការអនុវត្តនីតិវិធីសំណងរដ្ឋប្បវេណី»។

▪ **ខេត្តសៀមរាប** ប្រធានលេខាធិការដ្ឋាន បានទទួលជួបពិភាក្សាការងារជាមួយ៖ ១-អង្គការសម្ព័ន្ធចាប់ដៃ ស្តីពីការអនុវត្តសកម្មភាពរួមគ្នា រវាងគណៈកម្មាធិការគ.ខ.ប.ជខេត្ត និងអង្គការ។ ២-អង្គការអេ២១ ស្តីពីការផ្តល់សេវាដល់ករណីរំលោភបំពានតាមអនឡាញ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម, ការរៀបចំវេទិកាសាធារណៈ ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចតាមប្រព័ន្ធអនឡាញ។ ៣-អង្គការទស្សនៈពិភពលោក ស្តីពីយន្តការនៃការរាយការណ៍ និងការបញ្ជូននៅសហគមន៍ ដើម្បីចុះផ្សព្វផ្សាយបន្តតាមឃុំ។

▪ **ខេត្តក្រចេះ** ប្រធានលេខាធិការដ្ឋាន បានទទួលជួបពិភាក្សាការងារ ជាមួយអង្គការសកម្មភាពដើម្បីកុមារ ដើម្បីប្រមូលទិន្នន័យ និងលទ្ធផលគម្រោងរយៈពេល០៣ឆ្នាំ (២០២៣-២០២៥) របស់អង្គការ។

### គ. ការខារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ៥០លើក។ (ឧបសម្ព័ន្ធ)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយ ក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើ វិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់ នាំឱ្យឆកល្វែង ។
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ... ដែលធ្វើឱ្យការបូកសរុប ទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ជនល្មើសមានកលល្បិចជ្រៀតចូលធ្វើសកម្មភាពខុសច្បាប់ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់
- ខ្វះវិធីសាស្ត្រ និងសង្គតិភាពនៃសារអប់រំ ដែលមានប្រសិទ្ធភាព និងអាចបង្ការទប់ស្កាត់បាននូវអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់ទម្រង់។

### គ. សេចក្ដីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយ ឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើស ឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ករណីខ្លះ ជនល្មើស និងជនរងគ្រោះ ជាមនុស្សតែមួយ និងមានបណ្ដាញប្រទាក់ក្រឡាពីកន្លែងមួយ ទៅកន្លែងមួយ ពីប្រទេសមួយ ទៅប្រទេសមួយ។ ករណីភាគច្រើន មិនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែបង្កប់នូវបទល្មើសផ្សេងទៀត មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត គំនុំ ទំនាស់ការងារ ប្រព្រឹត្តខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេចពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលអាចការពារមិនឱ្យមនុស្សគ្រប់វ័យពីដំណាក់កាលដំបូង ដោយមិនរង់ចាំឱ្យដល់ដំណាក់កាលរងគ្រោះ ព្រោះវានឹងធ្វើឱ្យខូចខាត ទាំងធនធានមនុស្ស ធនធានថវិកា ពេលវេលា ទំនាក់ទំនងសង្គម និងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រម និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់ មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីរៀបចំចាត់តាំងមន្ត្រីទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ រួមទាំងមន្ត្រីលេខាធិការដ្ឋាន ទទួលបន្ទុក ការងាររបាយការណ៍ ផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ ដើម្បីងាយស្រួលដល់ការរៀបចំវគ្គបណ្ដុះបណ្ដាលតាមជំនាញសម្រាប់ការអនុវត្តការងារឲ្យទទួលបានប្រសិទ្ធភាពខ្ពស់
- ពង្រឹងកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងកិច្ចប្រជុំគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/រ.ប.ជ) ឱ្យបានទៀងទាត់ប្រចាំខែ ឬត្រីមាស ដើម្បីបូកសរុបរបាយការណ៍ វាយតម្លៃលើសកម្មភាព និងលទ្ធផលនៃការអនុវត្តផែនការតាមយុទ្ធសាស្ត្រនីមួយៗ។

## V. ទិសដៅត្រីមាសទី៤ ឆ្នាំ ២០២៥

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៣. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៤. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៥. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត

៦. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៧. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៨. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល

៩. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម៕

ថ្ងៃ...ចន្ទ ១៣រោច... ខែ...កត្តិក... ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី...១៧... ខែ...វិច្ឆិកា...ឆ្នាំ២០២៥

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជួ ម៉ិនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ
## ការដឹកនាំ សម្របសម្រួល

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ មជ្ឈមណ្ឌលផ្កាឈូក អង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ
  - ពិធីប្រកាសដាក់ឱ្យអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
  - អមអធិបតី ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងឱកាសជួបប្រជុំជាមួយ ឯកឧត្តម ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រ ក្នុងការផ្សព្វផ្សាយអំពីឱកាសការងារ ជូនដល់ប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់ពីប្រទេសថៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំក្រុមការងារ សម្របសម្រួលជូនប្រជាពលរដ្ឋជម្លៀសខ្លួន ពីតំបន់ព្រំដែន និងពលករកម្ពុជាដែលវិលត្រឡប់មកពីប្រទេសថៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំសម្តេចក្រឡាហោម (ជាន់ទី៩) ទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំ ស្តីពីការសម្របសម្រួលជូនដល់ប្រជាពលរដ្ឋ ដែលវិលត្រឡប់មកពីប្រទេសថៃ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមប្រព័ន្ធកម្មវិធី ZOOM
  - ជាគណអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារគណបក្ស ប្រចាំឆមាសទី១ ឆ្នាំ២០២៥ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ឆ្នាំង នៅសាលាខេត្តកំពង់ឆ្នាំង
  - ជាគណអធិបតី ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ នៃការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព ប្រចាំឆមាសទី១ ឆ្នាំ២០២៥ នៅសាលាខេត្តកំពង់ឆ្នាំង
  - កិច្ចប្រជុំឆ្លងសេចក្តីព្រាងសេចក្តីណែនាំ ស្តីពីចលនាប្រឡងប្រណាំងចំពោះបុគ្គលដែលមានស្នាដៃឆ្នើម ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព
  - កិច្ចប្រជុំផ្សព្វផ្សាយព្រឹត្តិការណ៍ និងគោលការណ៍សំខាន់ៗ ដោយសង្ខេបប្រចាំសប្តាហ៍ របស់អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ
  - ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តគម្រោង SAMICA ដំណាក់កាលទី២ ឆមាសទី១ ឆ្នាំ២០២៥ នៅសណ្ឋាគារភ្នំពេញអឺរ៉ា
  - ជាគណអធិបតី ក្នុងពិធីសំណេះសំណាលជាមួយមន្ត្រីរាជការ នៃរដ្ឋបាលក្រុងកំពង់ឆ្នាំង ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខេត្តកំពង់ឆ្នាំង នៅសាលាក្រុងកំពង់ឆ្នាំង
  - កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅសណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ
  - កិច្ចប្រជុំស្តាប់ការធ្វើបទបង្ហាញ ស្តីពីការអភិវឌ្ឍន៍ និងការដាក់ឱ្យដំណើរការប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ក្របខ័ណ្ឌក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ
  - រួមដំណើរជាមួយ ឯកឧត្តម តេង សួន អនុរដ្ឋលេខាធិការ ឯកឧត្តម ហែម ថេង អនុរដ្ឋលេខាធិការ ថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះបំពេញបេសកកម្មការងារ នៅខេត្តបន្ទាយមានជ័យ ដើម្បីសហការជាមួយអាជ្ញាធរខេត្ត និងស្ថាប័នពាក់ព័ន្ធ ជួយសម្របសម្រួលដល់ពលករខ្មែរ ដែលវិលត្រឡប់ពីប្រទេសថៃ នៅច្រកអន្តរជាតិប៉ោយប៉ែត
  - ដឹកនាំប្រតិភូក្រសួងមហាផ្ទៃ និងក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះពិនិត្យស្ថានភាព និងសួរសុខទុក្ខប្រជាពលរដ្ឋខ្មែរ ដែលត្រូវបានជម្លៀសចេញពីតំបន់ប្រឈមតាមខ្សែបន្ទាត់ព្រំដែន នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ និងច្រកអន្តរជាតិដូង ខេត្តបាត់ដំបង

- កិច្ចប្រជុំស្តាប់របាយការណ៍ ស្តីពីលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត របស់ក្រុមការងារត្រួតពិនិត្យឡើងវិញ (RPG) ក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
- ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយអគ្គលេខាធិការដ្ឋាន សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ នាំយកអំណោយមនុស្សធម៌ជូនដល់បងប្អូនក្រុមគ្រួសារវីរៈកងទ័ពជួរមុខ និងស្ត្រីមានផ្ទៃពោះ ស្ត្រីទើបសម្រាលកូន កូនតូច ជនចាស់ជរា ដែលកំពុងភៀសខ្លួនមកនៅជំរុំជនភៀសសឹកភ្នំកំបោរចំនួន៣៥០គ្រួសារ។ ជួបជាមួយកងកម្លាំងនគរបាល កងរាជអាវុធហត្ថ ប្រជាការពារ ១០០នាក់ បានសួរសុខទុក្ខវីរៈកងទ័ពដែលកំពុងសម្រាកព្យាបាលរបួស និងរងផ្សែងពុល នៅមន្ទីរពេទ្យបង្អែក ខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ ព្រមទាំងជូនអំណោយគ្រឿងឧបភោគបរិភោគ ដល់កងកម្លាំងឈរជើងនៅប្រាសាទតាមាន់ (ទីតាំងក្រៅសមរភូមិ) និងផ្ញើជូនអំណោយតាមរយៈស្នងការដ្ឋានខេត្តឧត្តរមានជ័យទៅកងកម្លាំងនគរបាលឈរជើងនៅព្រំដែនផងដែរ
- ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នាំយកនូវកញ្ចប់អំណោយមនុស្សធម៌ជូនដល់បងប្អូនក្រុមគ្រួសារមន្ត្រី នៃអាជ្ញាធរព្រះវិហារ ដែលបានជាប់គាំងនៅលើប្រាសាទព្រះវិហារ ក្នុងអំឡុងពេលទទួលការវាយប្រហារពីកងទ័ពថៃ និងកំពុងភៀសខ្លួនមកនៅជំរុំជនភៀសសឹក ខេត្តព្រះវិហារ
- ដឹកនាំក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះត្រួតពិនិត្យទីតាំងត្រៀមរៀបចំកម្មវិធី «ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៩» ឆ្នាំ២០២៥ ឱ្យបានល្អប្រសើរ នៅមជ្ឈមណ្ឌលសន្និបាត និងពិពណ៌អន្តរជាតិជ្រោយចង្វារ។
- កិច្ចប្រជុំបច្ចុប្បន្នភាពស្ថានភាពជម្លោះព្រំដែនកម្ពុជា-ថៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ
- ដឹកនាំក្រុមការងារថ្នាក់ដឹកនាំនារីក្រសួងមហាផ្ទៃ ចុះសួរសុខទុក្ខ និងប្រគល់ជូនស្នងការដ្ឋានខេត្តព្រះវិហារ ដើម្បីបញ្ជូនទៅវរៈនគរបាលព្រំដែនទាំង៦ នៅទិសព្រះវិហារ និងឧត្តរមានជ័យ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជួបសំណេះសំណាលជាមួយកងកម្លាំងនគរបាល នៃស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ
- ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជួបសំណេះសំណាល និងនាំយកនូវគ្រឿងសម្ភារៈបរិក្ខារមួយចំនួន ឧបត្ថម្ភដល់មន្ត្រីនគរបាលសុខាភិបាល នៃមន្ទីរពេទ្យ១៦ឧសភា ចំនួន១៥រូប ដែលបានវិលត្រឡប់ពីការបំពេញបេសកកម្មប្រចាំការថែទាំសុខភាពកងកម្លាំងនគរបាលការពារព្រំដែនជួរមុខ នៅសាលប្រជុំមន្ទីរពេទ្យ១៦ឧសភា
- កម្មវិធីអបអរសាទរខួបអនុស្សាវរីយ៍នៃការទទួលបានឯករាជ្យ លើកទី៧៩ របស់សាធារណៈរដ្ឋឥណ្ឌា នៅសណ្ឋាគារសូហ្វីតែល ភូគីត្រា រាជធានីភ្នំពេញ
- ដឹកនាំកិច្ចប្រជុំក្រុមការងារពិធីការ ក្រុមាការងារសន្តិសុខ និងតំណាងសាសនានានា ដើម្បីពិភាក្សាអំពីដំណើរការរៀបចំទិវាជាតិអន្តរសាសនាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៩ ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌលសន្និបាត និងពិពណ៌អន្តរជាតិជ្រោយចង្វារ
- ជាគណៈអធិបតី ក្នុងពិធីជួបសំណេះសំណាល ជាមួយប្រជាពលករដែលវិលត្រឡប់មកពីប្រទេសថៃ និងគ្រួសារកងទ័ពក្នុងខេត្តកំពង់ឆ្នាំង សរុប ៥៨គ្រួសារ និងគ.ជ.ប.ជ បន្ថែមជាកញ្ចប់សម្ភារៈ ១៣មុខ និងថវិកា៥០.០០០រៀល សម្រាប់គ្រួសារទាំង៥៨ និងបន្ថែមថវិកា ១០ម៉ឺនរៀល ដល់គ្រួសារទ័ព ទាំង១៩គ្រួសារ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេសប្រធានក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានខេត្តកំពង់ឆ្នាំង នៅសាលប្រជុំសាលាក្រុងកំពង់ឆ្នាំង
- ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចុះសួរសុខទុក្ខ ដោយនាំយកនូវកញ្ចប់អំណោយមនុស្សធម៌ ដែលឧបត្ថម្ភដោយអង្គការ HAGAR ជូនដល់បងប្អូនក្រុមគ្រួសារវីរៈកងទ័ពជួរមុខ ដែលកំពុងភៀសខ្លួនមកនៅជំរុំជនភៀសសឹក នៅក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ
- កិច្ចប្រជុំពិភាក្សាការងារបន្ទាន់ ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ

- ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមកិច្ចពិភាក្សាកម្រិតថ្នាក់ដឹកនាំ ស្តីពីការរៀបចំថវិកាសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ដឹកនាំប្រតិភូក្រសួងមហាផ្ទៃ ចូលរួមកិច្ចប្រជុំជាមួយក្រុមប្រឹក្សាអ្នកច្បាប់ដើម្បីពិនិត្យ និងពិភាក្សាលើករណីគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីផ្ទេរការងារដឹកនាំ និងសម្របសម្រួលនៃក្រុមការងារកម្ពុជា ប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ (ក្រុមការងារខមមីតកម្ពុជា) នៅក្នុងក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី
- ជាអធិបតី វគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងចំណាកស្រុកដោយគ្មានសុវត្ថិភាព និងជម្រើសមុខរបរនិងការងារ ជូនដល់និស្សិតនៅវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប
- កិច្ចប្រជុំគណៈកម្មាធិការកណ្តាល សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ដឹកនាំដោយ លោកជំទាវ **មាន សំអាន** អនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍
- ដឹកនាំក្រុមការងារ រួមមាន ឯកឧត្តម **តេង សួន** ឯកឧត្តម **ហែម ថេង** ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ នៃគ.ជ.ប.ជ ចុះពិនិត្យស្ថានភាព សាកសួរសុខទុក្ខ និងនាំយកសម្ភារៈប្រើប្រាស់ចែកជូនដល់ប្រជាពលរដ្ឋ រស់នៅចំណុចព្រំដែន ស្ថិតនៅភូមិព្រៃចាន់ ឃុំព្រៃចាន់ និងភូមិជោគជ័យ ឃុំអូបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ
- ដឹកនាំក្រុមការងារ រួមមាន ឯកឧត្តម **ម៉ៅ សំបុណ្យ** ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ នៃគ.ជ.ប.ជ ចុះផ្សព្វផ្សាយ ស្តីពី «ការចុះជួបសំណេះសំណាល សួរសុខទុក្ខ ត្រួតពិនិត្យកម្លាំង និងផ្សព្វផ្សាយខ្លឹមសារច្បាប់ស្តីពីសញ្ជាតិ» នៅស្នងការដ្ឋាននគរបាល ខេត្តកំពង់ឆ្នាំង មានវត្តមានមន្ត្រីនគរបាលជាតិ មកពីស្នងការដ្ឋាន អធិការដ្ឋាន និងប៉ុស្តិ៍នគរបាលរដ្ឋបាលទាំង ៤១ ទូទាំងខេត្ត
- ដឹកនាំប្រតិភូអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានការសម្របសម្រួល ពីឯកឧត្តមក្រុមប្រឹក្សាខេត្ត និងលោកអភិបាលរងខេត្តបន្ទាយមានជ័យ ចុះពិនិត្យស្ថានភាព សួរសុខទុក្ខ និងបានឧបត្ថម្ភថវិកាលើកទឹកចិត្ត ដល់កម្លាំងដែលកំពុងឈរជើងនៅចំណុចព្រំដែន ភូមិព្រៃចាន់ ឃុំព្រៃចាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ និងបាននាំយកនូវទេយ្យទានប្រគេនដល់ព្រះសង្ឃគង់នៅវត្តសុវណ្ណសិក្ខារាម ភូមិព្រៃចាន់ និងវត្តពុទ្ធិសីមារាម ជោគជ័យ ភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ **ប៉ុណ្ណ សំខាន** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - ដឹកនាំមន្ត្រី នៃអគ្គលេខាធិការដ្ឋានចំនួន ២០រូប ដើម្បីចូលរួមវិធីផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋាន ស្តីពីបញ្ហាគ្រឿងញៀន របស់គណៈកម្មាធិការសម្របសម្រួល ជំរុញ អនុវត្ត និងត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព ឯកឧត្តម **កៅ ខុនដារ៉ា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ពិនិត្យមាតិកាលើប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ប្រាក់ ច័ន្ទណយ** រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ នៅទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
  - សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ដោយផ្តោតលើកស្តុតាង និងឬសក្ខីកម្មដែលបានថតទុកជាវីដេអូ ក្រោមអធិបតីភាព ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ នៅសណ្ឋាគារកាំបូឌីយ៉ាណា
  - កិច្ចប្រជុំត្រៀមសម្រាប់ពិធី ជំនួបសម្តែងការគួរសម រវាង ឯកឧត្តម សន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងកុងស៊ុលកិត្តិយស ចំនួន ៨ប្រទេស ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ
  - ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយកុងស៊ុល នៃបណ្តាប្រទេសសមាជិកសហភាពអឺរ៉ុបចំនួន ៨ប្រចាំកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងមានវត្តមានរបស់ ឯកឧត្តម Salah Essa ប្រធានកុងស៊ុលនៃបណ្តាប្រទេសសមាជិកសហភាពអឺរ៉ុប និងជាកុងស៊ុលសាធារណរដ្ឋស៊ីប (Cyprus) ព្រមទាំងកុងស៊ុលកិត្តិយស របស់ប្រទេសអូទ្រីស បារាំង អ៊ីតាលី ហូឡង់ ន័រវេស និងហ្វាំងឡង់ នៅទីស្តីការក្រសួងមហាផ្ទៃ

- សិក្ខាសាលាប្រមូលលទ្ធផលគម្រោង (ស្គូល) ឆ្នាំទី៣ ដើម្បីបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ច និងរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ
- សន្និសីទថ្នាក់តំបន់ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ និងជំនាញ ដើម្បីប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ នៅខេត្តសៀមរាប។

- **លេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (៤៧ច្បាប់) លិខិតចូល (៥៧ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(៨៨ច្បាប់)លិខិតចូល(៦៨ច្បាប់)
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - ចូលរួមសិក្ខាសាលាប្រមូលលទ្ធផលគម្រោង(ស្គូល)ឆ្នាំទី៣ រៀបចំដោយអង្គការ Terre des Hommes Netherland។
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - ចូលរួមកម្មវិធីផ្សព្វផ្សាយ ស្តីពីមូលដ្ឋានគ្រឹះនៃជម្ងឺអេដស៍ និងវិធីសាស្ត្របង្ការទប់ស្កាត់ការឆ្លងជម្ងឺដល់មន្ត្រីជំនាញ កីឡាករ និងកីឡាការិនី ក្រោមអធិបតីភាព លោកជំទាវ **អុង សុភារី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជម្ងឺអេដស៍កាមរោគ នៅទីស្តីការក្រសួងមហាផ្ទៃ
  - ចូលរួមសិក្ខាសាលា ស្តីពីអនុសាសន៍ និងនីតិវិធីវាយតម្លៃ អញ្ញមញ្ញសកលជុំទី៥ របស់ក្រុមការងារហិរញ្ញវត្ថុ សម្រាប់អាជ្ញាធរអនុវត្តន៍ច្បាប់ ក្រោមអធិបតីភាព ឯកឧត្តម **ហេង បូមករា** ប្រធានអង្គភាពស៊ើបអង្កេតហិរញ្ញវត្ថុ
- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**
  - ចូលរួមសិក្ខាសាលាត្រីភាគី ត្រៀមថ្នាក់ជាតិសម្រាប់កម្ពុជាវេទិកាអាស៊ានលើកទី១៨ ស្តីពីទេសន្តរប្រវេសន៍ការងារ ក្រោមប្រធានបទ «ការពន្លឿនសកម្មភាពឆ្ពោះទៅមុខរកគោលដៅអភិវឌ្ឍន៍ ប្រកបដោយចិរភាព ស្តីពីការធ្វើទេសន្តរប្រវេសន៍ក្របកដោយសុវត្ថិភាព និងការងារសមរម្យ សម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងតំបន់អាស៊ាន» ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅសណ្ឋាគារកាំបូឌីយ៉ាណា
  - ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទ កុមារតាមប្រព័ន្ធអនឡាញ ក្រោមការរៀបចំពីអង្គការ Auscam freedoms projeet ដែលមានក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ នៅសាលប្រជុំសាន់អេនមូន រាជធានីភ្នំពេញ។
- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - ចូលកិច្ចប្រជុំពិភាក្សាដើម្បីពិនិត្យ និងរៀបចំធាតុចូល សម្រាប់សេចក្តីព្រាងសុន្ទរកថា គោរពជូន សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ថ្លែងក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅថ្ងៃទី២៦-២៨ ខែតុលា ឆ្នាំ២០២៥ ដឹកនាំដោយ ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ SOMTC-កម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ
  - ចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើការរៀបចំរបាយការណ៍ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) នៅទីស្តីការក្រសួងមហាផ្ទៃ។
- **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**
  - សិក្ខាសាលាពិគ្រោះយោបល់ ស្តីពីតុលាការដែលយកចិត្តទុកដាក់ចំពោះជនរងគ្រោះ ដោយផ្តោតលើភស្តុតាង និងប្តូរសក្ខីកម្មដែលបានថតទុកជាវីដេអូ ក្រោមអធិបតីភាព ឯកឧត្តម **កេង សុម៉ាវិទ្ធ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌
  - ចូលរួមកិច្ចប្រជុំត្រួតពិនិត្យទិន្នន័យរបាយកាណ៍ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី។